ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣៧ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ទំ

មាតិកា

I . ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

១១-១០-១៩៩៥ –អនុក្រឹត្យលេខ ៧៦ អនក្រ.បក ស្តីពីការកែលំអ និងបំពេញបន្ថែមអនុក្រឹត្យ ស្តីពីការប្រមូលពន្ធតែមប្រិ៍សារពើពន្ធ ១៩២៤

១២-១០-១៩៩៥- អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្តីពីការចំណាយឥតគ្រោងទុក ១៩២៨

១២-១០-១៩៩៥- អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្តីពីការបែងចែកជំពូកចំណាយឥតគ្រោងទុក នៃថវិការដ្ឋ ឆ្នាំ ១៩៩៥ ១៩២៩

១៣-១០-១៩៩៥- អនុក្រឹត្យលេខ ៧៩ អនក្រ.បក ស្តីអំពីបុរិសណ្ឋាគារ ១៩៣០

១១-១០-១៩៩៥- អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៣៤

១២-១០-១៩៩៥- អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្តីពីការពន្យារពេលចូលនិវត្តន៍មន្ត្រីរាជការ ១៩៣៥

២ - សេចក្តីសំរេច

១១-១០-១៩៩៥- សេចក្តីសំរេចលេខ ៧០ សសរ ស្តីពីការបង្កើតក្រុមការងារសំរាប់ផ្តល់យោបល់លើរបាយការណ៍ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជារបស់លោក មៃកែលគើប៊ី ១៩៣៦

១២-១០-១៩៩៥- សេចក្តីសំរេចលេខ ៧១ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៩៣៨

១២-១០-១៩៩៥- សេចក្ដីសំរេចលេខ ៧២ សសរ ស្ដីពីការផ្ទេរសិទ្ធិ ១៩៣៩

II . ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២-១០-១៩៩៥- ប្រកាសលេខ ៣៣៦ ប្រក. សហវថ ស្ដីពីការបំពេញបន្ថែម ចំណាត់ថ្នាក់ចំណូលថវិកាទូទៅរបស់រដ្ឋ ១៩៤១

២- ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

០៩-១០-១៩៩៥ - ប្រកាសលេខ ៧៦២ ផក. ប្រក. ស្ដីពីការតម្លើងថ្លៃលក់ថាមពល អគ្គិសនីដល់អ្នកធ្វើសេវាកម្មចែកចាយថាមពលអគ្គិសនី ១៩៤៣

១០-១០-១៩៩៥ - ប្រកាសលេខ ៧៧១ បល. ប្រក. ស្ដីពីការបង្កើតគណៈកម្មការ រៀបចំតម្លើងកាំប្រាក់ប្រចាំឆ្នាំ ១៩៤៤

៣- ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

០៩-១០-១៩៩៥ - ប្រកាសលេខ ២៥២/៩៥ ពម. ប្រក. ស្ដីពីការផ្លាស់ប្ដូរ កន្លែងធ្វើការរបស់មន្ត្រីរាជការ ១៩៤៥

១០-១០-១៩៩៥ - ប្រកាសលេខ ២៥៣/៩៥ ពម. ប្រក ស្ដីពីការផ្លាស់ប្ដូរ កន្លែងធ្វើការរបស់មន្ត្រីរាជការ ១៩៤៦

១០-១០-១៩៩៥ - ប្រកាសលេខ ២៥៤/៩៥ ពម. ប្រក ស្ដីពីការផ្ទេរការងារ មន្ត្រីរាជការរបស់ក្រសួងពត៌មាន ១៩៤៧

១០-១០-១៩៩៥ – ប្រកាសលេខ ២៥៥/៩៥ ពម.ប្រក អនុញ្ញាតអោយ
ទស្សនាវដ្តី«វិទ្យាយុទ្ធ» បោះពុម្ពផ្សាយ ១៩៤៨
១១-១០-១៩៩៥ – ប្រកាសលេខ ២៥៧/៩៥ ពម.ប្រក ស្តីពីការលុប
ឈ្មោះមន្ត្រី រាជការ ១៩៤៩

៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១២-១០-១៩៩៥ – ប្រកាសលេខ ១៦៥១ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលា
បឋមសិក្សា ភូមិគោល មកជាសាលាបឋមសិក្សា«ហ៊ុន សែន»
«ភូមិគោល » ១៩៥០
១២-១០-១៩៩៥ – ប្រកាសលេខ ១៦៥២ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលា
ឧបសម្ព័ន្ធបឋមសិក្សា ទន្សាស្ទិត ទៅជាសាលាបឋមសិក្សា
«ព្រៃគោល » ១៩៥២
១២-១០-១៩៩៥ – ប្រកាសលេខ ១៦៥៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលា
បឋមសិក្សា អំពិលបី មកជាសាលាបឋមសិក្សា «ទេពប្រណម្យ» ១៩៥៣
១២-១០-១៩៩៥ – ប្រកាសលេខ ១៦៥៤ អយក.ប្រក ស្តីពីការទទួលស្គាល់
សាលាបឋមសិក្សាត្រពាំងរការ និងសាលាបឋមសិក្សា អង្គស្វែង ១៩៥៥

៥- ទីស្តីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

១០-១០-១៩៩៥ – ប្រកាសលេខ ១៨៧៧ បស្ថ ស្តីពីការទទួលស្គាល់ និងប្រគល់
ភារកិច្ចជូនមន្ត្រីរាជការ ១៩៥៦

៦- ទីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

១១-១០-១៩៩៥ – សេចក្តីសំរេច លេខ ២១៣/៩៥ កធស ស្តីពីការទទួលស្គាល់ ព្រះវិហារ ធានអ៊ីម៉ីលីក ១៩៥៨

១១-១០-១៩៩៥ – សេចក្តីសំរេច លេខ ២១៤/៩៥ កធស ស្តីពីការអនុញ្ញាត បើកស្នាក់ការសហព័ន្ធក្រុមជំនុំគ្រិស្តបរិស័ទខ្មែរបាប់ទីស្ត ខេត្តព្រៃវែង ១៩៥៩

១១-១០-១៩៩៥ – សេចក្តីសំរេច លេខ ២១៥/៩៥ កធស ស្តីពីការអនុញ្ញាត ច្បាប់អោយបង្កើតសាខាព្រះវិហារសាសនា ព្រះយេស៊ូគ្រិស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ១៩៦១

១០-១០-១៩៩៥ – ប្រកាសលេខ ២២៣/៩៥ កធស.ប្រក ស្តីពីការផ្លាស់ប្តូរ កន្លែងធ្វើការរបស់មន្ត្រីរាជការ ១៩៦២

៧- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

១១-១០-១៩៩៥ – ប្រកាសលេខ ១០៣៤ បស.បល ស្តីពីការអនុញ្ញាតអោយ ផ្អាកការងារដោយគ្មានបៀវត្ស ១៩៦៣

៨- ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

១១-១០-១៩៩៥–ប្រកាសលេខ ១៥៩ បទ.យក ស្តីពីការលុបឈ្មោះមន្ត្រី បុគ្គលិក រាជការ ១៩៦៥

I- ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៧៦ អនក្រ.បក

ស្តីពី

ការកែលំអ និង បំពេញបន្ថែមអនុក្រឹត្យ

ស្តីពីការប្រមូលពន្ធតែមប្រិ៍សារពើពន្ធ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើអោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការបង្កើតតែមប្រិ៍សារពើពន្ធ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ២៣ ក្រ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩១
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩១ ស្តីពីការប្រមូល ពន្ធតែមប្រើសារពើពន្ធ
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១: ត្រូវបានកែប្រែតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩១ មកជាតារាងពន្ធតែមប្រើដូចខាងក្រោម ÷

តារាងពន្ធតែមប្រើ

ល.រ	បរិយាយ	កំរិតពន្ធតែមប្រើ សារពើពន្ធ	សេចក្តី ផ្សេៗ
	I-**ក្រុមចាប់ពន្ធតែមប្រើតាមការកំណត់**		
១	លិខិតស្នើសុំចូលរៀនមធ្យមសិក្សា	១០០៛	
២	លិខិតស្នើសុំប្រលងយកសញ្ញាប័ត្រ	៣០០៛	
៣	លិខិតស្នើសុំចូលរៀន និង ប្រលងចូលរៀនមហាវិទ្យាល័យក្នុង–ក្រៅប្រទេសសាលាវិជ្ជាជីវៈនានា	៦០០៛	
៤	លិខិតស្នើសុំចូល និងប្រលងចូលធ្វើការ	១.២០០៛	
៥	លិខិតប្តឹងទោស	១.២០០៛	
៦	លិខិតស្នើសុំប្រលងបើកបរយានយន្តគ្រប់ប្រភេទ	២.០០០៛	
៧	លិខិតស្នើសុំចូលដេញថ្លៃឡូត៍នេសាទ–ព្រៃគុប	៥.០០០៛	
៨	លិខិតស្នើសុំបង្កើតក្រុមហ៊ុនអាហារណ៍–នីហរណ៍សណ្ឋាគារ វិយោគទុនបរទេស	៥.០០០៛	
៩	លិខិតស្នើសុំប្រកបអាជីវកម្មផ្សេងៗ	២.០០០៛	
១០	លិខិតស្នើសុំផ្តល់ផ្លាកលេខសំគាល់យានយន្តគ្រប់ប្រភេទ	១.៥០០៛	
១១	លិខិតស្នើសុំផ្សេងៗ	១.០០០៛	

១២	ពាក្យបណ្តឹងគ្រប់ប្រភេទ	១.៥០០៛	
១៣	លិខិតបញ្ជាក់កិរិយា មារយាទ ប្រវត្តិរូប បញ្ជាក់ទីលំនៅ «ដើមឬ ចំលង»	៣០០៛	១ ទំព័រ
១៤	សំបុត្រកំណើត «ដើមឬចំលង»	២០០៛	១ ទំព័រ
១៥	សំបុត្រមរណភាព «ដើមឬចំលង»	៣០០៛	១ ទំព័រ
១៦	សំបុត្រអាពាហ៍ពិពាហ៍ «ដើមឬចំលង»	១.៥០០៛	១ ទំព័រ
១៧	លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្មនានា «ដើមឬចំលង»	៥.០០០៛	១ ទំព័រ
១៨	ប័ណ្ណសំគាល់គ្រឿងក្រយាន	២.០០០៛	
១៩	ប័ណ្ណសំគាល់គ្រឿងក្រយានយន្ត	៣.០០០៛	
២០	ប័ណ្ណសំគាល់ទោចក្រយានយន្ត	២.០០០៛	
២១	ប័ណ្ណសំគាល់រថយន្តគ្រប់គ្រង	៣.០០០៛	
២២	ប័ណ្ណសំគាល់ផលយាន	១.០០០៛	
២៣	ប័ណ្ណ[illegible]យានយន្ត	៣.០០០៛	
២៤	ប័ណ្ណបើកបរយ[illegible]ប្រភេទ	៣.០០០៛	
២៥	សេចក្តីអនុញ្ញាតអោយប្រកបអាជីកម្មអាហារណ៍–ទីហរណ៍សណ្ឋាគារវិនិយោគទុនបរទេស	១០.០០០៛	
២[illegible]	សេចក្តីអនុញ្ញាតអោយប្រកបអាជីវកម្មផ្សេង ៗ	៥.០០០៛	
២៧	លិខិតបញ្ជាក់ លិខិតបកប្រែ	៥.០០០៛	
	II-<u>ត្រូវបង់ពន្ធតែមប្រើតាមទំហំ និងតាមផ្ទៃក្រដាស</u>		១ ទំព័រ
	ក–<u>ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយ : ក្រដាសធម្មតា</u>		
២៨	មានផ្ទៃមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា	៥០០៛/ទំព័រ	បើមានអក្សរបរទេស ១.៥០០៛/ទំព័រ
២៩	មានផ្ទៃលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា	៧០០៛/ទំព័រ	បើមានអក្សរបរទេស ២.១០០៛/ទំព័រ

	ខ—ប័ណ្ណប្រកាសផ្សាយ		
	ពាណិជ្ជកម្មធ្វើពីក្រដាស		
	ក្រណាត់ ឬ វត្ថុធាតុផ្សេង ៗ		
	មានផ្ទៃមិនលើសពី ៤០	៧០០៛ ផ្ទាំង	បើមានអក្សរបរទេស
	ដេស៊ីម៉ែត្រក្រឡា		២.១០០៛ ផ្ទាំង
៣១	មានផ្ទៃលើសពី ៤០ ដល់ ១០០		
	ដេស៊ីម៉ែត្រ		
៣២	ផ្ទៃធំលើសពី ១០០ដេស៊ីម៉ែត្រ	១.០០០៛ ផ្ទាំង	បើមានអក្សរបរទេស
	ក្រឡា ត្រូវគិតជាផ្ទាំងអក្សរ»		៣.០០០៛/ ផ្ទាំង
	គ—ផ្លាកអាជីវកម្មដ្ឋាននានា:		បើមានអក្សរបរទេស ត្រូវគិតបន្ថែម
៣៣	គ្មានពន្លឺលើកស្របផងផ្លូវសាធារណៈ	១០០៛ដម២ ឆ្នាំ	−២០០៛ | ក្នុងអក្សរមួយតួនិង
៣៤	គ្មានពន្លឺកែងផ្លូវសាធារណៈ	១៥០៛/ដម២/ឆ្នាំ	−៣០០៛ | ក្នុងពាក្យមួយដេស៊ី
៣៥	មានពន្លឺលើកស្របផងផ្លូវសាធារណៈ	២០០៛/ ដម២/ ឆ្នាំ	−៤០០៛ | ម៉ែត្រក្រឡាការេ
៣៦	មានពន្លឺកែងផ្លូវសាធារណៈ	២៥០/ដម២/ ឆ្នាំ	−៥០០៛
	ឃ—ផ្ទាំងស្លាកផ្ទាំងរូបភាព		បើមានអក្សរបរទេស
	លើកន្លែងនានាសម្រាប់ផ្សាយ		ត្រូវគិតបន្ថែម
	ពាណិជ្ជកម្ម		
៣៧	គ្មានពន្លឺលើកស្របផងផ្លូវសាធារណៈ	៥០០៛/ដម២ ឆ្នាំ	−១.០០០៛ | ក្នុងអក្សរមួយតួនិង
៣៨	គ្មានពន្លឺកែងផ្លូវសាធារណៈ	៧០០៛/ដម២/ ឆ្នាំ	−១.៤០០៛ | ក្នុងពាក្យមួយដេស៊ី
៣៩	មានពន្លឺលើកស្របផងផ្លូវសាធារណៈ	៧[illegible]/ដម២/ឆ្នាំ	−១.៤០០៛ | ម៉ែត្រ ឬ ប្រភាគ
៤០	មានពន្លឺកែងផ្លូវសាធារណៈ	១.០០០៛ ដម២/ឆ្នាំ	−២.០០០៛
៤១	ដាក់ភ្ជាប់ឬគូរភ្ជាប់	១.៥០០៛/ដម២/ឆ្នាំ	−៣.០០០៛
	និងមធ្យោបាយដឹកជញ្ជូននានា		

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី នៃក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ និង អភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួន ។

មាត្រា ៣ : អនុក្រឹត្យនេះ មានអនុភាពគតិយុត្តចាប់ពីថ្ងៃដែលប្រកាសផ្សាយជាសាធារណៈ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៧៧ អនក្រ.បក
ស្តីពីការចំណាយផអង្គ្រាខទុក

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស ឆ្នាំ ១៩៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

– បានឃើញច្បាប់ ស្តីអំពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស.រកម ០៩៩៥.០១ ចុះថ្ងៃទី ០១ ខែ កញ្ញ ឆ្នាំ ១៩៩៥

– តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ផ្តល់ឥណទានបន្ថែមដោយដកពីជំពូក ៤១ «ចំណាយឥតគ្រោងទុក » នៃថវិការ ចំនួន ១០៨.០០០.០០០ រៀល «មួយរយប្រាំបីលានរៀលគត់ » ជូនទៅក្រសួងសង្គ កិច្ច ការងារ និង អតីតយុទ្ធជន ជំពូក ១១ ចំណាយដំណើរការរដ្ឋបាល សំភារ និង ជួសជុលតូច ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីយុទ្ធជន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៧៨ អនក្រ.បក

ស្តីពីការបែងចែកជំពូកចំណាយឥតគ្រោង ទុក នៃថវិការដ្ឋឆ្នាំ ១៩៩៥

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ហិរញ្ញវត្ថុ កែតម្រូវសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : អនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃថវិការដ្ឋ ចំនួន ៥៩.០០០.០០០៖០០ (ហាសិបប្រាំបួនលានរៀលគត់) បញ្ចូលទៅជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ផ្គត់ផ្គង់តូច) របស់ក្រសួងផែនការ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * * *

ភ្នំពេញ , ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ៧៩ អនក្រ.បក

ស្តីអំពីបុរីសណ្ឋាគារ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពារ រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ (អាជ្ញាធរអប្សរា)
- បានឃើញព្រះរាជក្រឹត្យ ស្តីអំពីការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់អនុម័តនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីអំពីការរៀបចំ តំបន់ និងការគ្រប់គ្រងតំបន់សៀមរាបអង្គរ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

សម្រេច

ជំពូកទី ១

បុរីសណ្ឋាគារ

មាត្រា ១ : តំបន់ទាំងមូលដែលកំណត់ដោយអក្សរ « ក » ដូចមានកំណត់ក្នុងប្លង់ភ្ជាប់ជាមួយនេះជាកម្មសិទ្ធិ របស់ព្រះរាជាណាចក្រកម្ពុជា នៅទីរួមខេត្តសៀមរាប ហើយត្រូវបានប្រគល់អោយអាជ្ញាធរ «អប្សរា» គ្រប់គ្រង និងចាត់ចែងធ្វើជាបុរីសណ្ឋាគារ ។

ទីតាំងនៃបុរីសណ្ឋាគារនេះមានទំហំដីចំនួន ៥៦០ ហិកតា ស្ថិតនៅត្រង់ចំណុចចន្លោះ ចាប់ពី ÷

- ចំណុច១ ខ្សែរយៈបណ្តោយ ៣៧៧៤០០ ខ្សែរយៈទទឹង ១៤៧៨០០០
- ចំណុច២ ខ្សែរយៈបណ្តោយ ៣៧៨១៥០ ខ្សែរយៈទទឹង ១៤៧៩៧០០
- ចំណុច៧ ខ្សែរយៈបណ្តោយ ៣៨១០០០ ខ្សែរយៈទទឹង ១៤៧៩៧២០
- ចំណុច៨ ខ្សែរយៈបណ្តោយ ៣៨១០០០ ខ្សែរយៈទទឹង ១៤៧៨០០០

មាត្រា ២ : រាល់ការប្រើប្រាស់ ការប្រកាន់យកជាកម្មសិទ្ធិព្រមទាំងការផ្ទេរសិទ្ធិដីធ្លីទាំងអស់នៅក្នុងតំបន់នេះ ក្រោយពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានមិនអាចទទួលស្គាល់ ថាត្រឹមត្រូវតាមច្បាប់ឡើយ ។

មាត្រា ៣ : អាជ្ញាធរ «អប្សរា» ជាអ្នកអភិបាលតំបន់បុរីសណ្ឋាគារនេះ និងទទួលខុសត្រូវលើ ÷

- ការគ្រប់គ្រងចាត់ចែង
- ការថែរក្សាការពារមិនអោយមានការចាប់យកដីធ្លីថ្មីទៀត
- ការរៀបចំ ព្រមទាំងការដាក់អោយធ្វើអាជីវកម្មដីធ្លីគ្រប់បែបយ៉ាង ។

មាត្រា ៤ : រាល់បុគ្គលទាំងឡាយដែលបានកាន់កាប់ស្របច្បាប់នូវដីតិច ឬច្រើនក្នុងតំបន់នេះតាំងពីមុនពេល អនុក្រឹត្យនេះចូលជាធរមាន ត្រូវមកផ្តល់ពត៌មានដល់អាជ្ញាធរ «អប្សរា» ក្នុងរយៈពេលយ៉ាងយូរ បំផុតមួយឆ្នាំ គិតពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាលើអនុក្រឹត្យនេះ ព្រមទាំងយកមក ជាមួយនូវភ័ស្តុតាងនៃការកាន់កាប់ដីដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច ។

ជំពូកទី ២

តំបន់ដែលត្រូវយកចិត្តទុកដាក់ជាពិសេស

មាត្រា ៥ : ស្របតាមព្រះរាជក្រឹត្យ ស្តីពីការកំណត់និងរៀបចំតំបន់សៀមរាបអង្គរ លេខ ០០១ នស ចុះ ថ្ងៃ ២៨ ឧសភា ឆ្នាំ ១៩៩៤ ហើយនិងរបាយការណ៍ភ្ជាប់ ស្តីអំពីតំបន់ទីក្រុងដែលត្រូវថែរក្សា ការពារ ÷

ក–)ត្រង់ចំណុច (៣០–៣១–៣២) ត្រូវបានប្រកាសថា :តំបន់បញ្ញត្តិប្រើប្រាស់ដីក្នុងទទឹង ២៥០ម ម្ខាងៗនៃផ្លូវជាតិលេខ ៦ (មើលប្លង់អក្សរ «ខ ») ។

ខ–)ត្រង់ចំណុច ៣៩ ស្តីអំពីមាត់ច្រាំងស្ទឹងសៀមរាប និងស្ទឹងរលួសដែលត្រូវការពារមាន ទទឹង ៥០០ម ពីច្រាំងម្ខាងៗនៃស្ទឹងសៀមរាប (មើលប្លង់អក្សរ«គ») និងស្ទឹងរលួស ។

គ–)អំពីការគ្រប់គ្រងទេសភាព ហើយនិងសម្បត្តិធម្មជាតិត្រូវបានប្រកាសថា : តំបន់ត្រូវបានការ ពារ (មើលប្លង់អក្សរ«ឃ») ដែលនៅចន្លោះផ្លូវជាតិលេខ ៦ ពីខាងត្បូង និងពីខាងជើង គឺ ត្រង់ព្រំប្រទល់តំបន់ ២ ជាតំបន់ត្រូវការពារនៃឧទ្យានបុរាណវិទ្យា ។

តំបន់ទាំងនេះជាកម្មវត្ថុដែលត្រូវមានវិធានការពិសេសដោយឡែក ។ រាល់ទង្វើដើម្បី បែងចែក ឬរួមបញ្ចូលដីឡូត៍ដែលមានស្រាប់ ព្រមទាំងរាល់គំរោងកែប្រែទ្រង់ទ្រាយទាំងមូល ពាក់ព័ន្ធដល់តំបន់ទាំងនេះ ត្រូវតែដាក់ឆ្លងសុំការអនុញ្ញាតពីអាជ្ញាធរ «**អប្សរា**»ជាមុនសិន ។

មាត្រា ៦ : រាល់បទបញ្ញត្តិទាំងឡាយណាផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការនៃស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**


ROYAUME DU CAMBODGE "A.P.S.A.R.A." ETUDE DU PLAN D'URBANISME ET PROJETS PRIORITAIR
Novembre 1994


N

ភ្នំពេញ , ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ១១២ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីអំពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមនីយដ្ឋាន និង រៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរ «**អប្សរា**»
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរ «**អប្សរា**»

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **វស់ ប៊ុវ៉ាត** ជាអគ្គនាយកអាជ្ញាធរ ដើម្បីការពាររមនីយដ្ឋាន និង រៀបចំ តំបន់អង្គរ ហៅថា អាជ្ញាធរ «**អប្សរា**» ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី គ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន សមាជិកនៃក្រុមប្រឹក្សា ភិបាលអាជ្ញាធរ ដើម្បីការពាររមនីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ «**អប្សរា**» និងលោក **វស់ ប៊ុវ៉ាត** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

ភ្នំពេញ , ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ ១១៣ អនក្រ.តត

ស្តីពីការពន្យារពេលចូលនិវត្តន៍មន្ត្រីរាជការ

* * * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត់ ១០៩៤–៩០ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងមាត្រា ៦៣ ជំពូកទី ១០ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់សមាគមនិស្សិតមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ
- តាមសេចក្តីត្រូវការចាំបាច់

សំរេច

មាត្រា ១ : យល់ព្រមពន្យារពេលចូលនិវត្តន៍ចំនួន ១ឆ្នាំតទៅទៀតសំរាប់លោក **ឈុន គីមអាន** គ្រូឧបុរសរង ដោយគិតចាប់ពីថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន រដ្ឋលេខាធិការ[illegible]

លេខាធិការដ្ឋានមុខងារ សាធារណៈ ព្រមទាំងលោក ឈុន គីមអាន ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថ លេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២- សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៧០ សសរ

ស្តីពីការបង្កើតក្រុមការងារសំរាប់ផ្តល់យោបល់លើ

របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជារបស់លោក

ម៉ៃ គែល គើប៊ី

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ផ្អែកតាមការចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានបង្កើតក្រុមការងារមួយសំរាប់ផ្តល់យោបល់លើរបាយការណ៍ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា របស់លោក **ម៉ៃ គែលគើប៊ី** តំណាងពិសេសរបស់លោកអគ្គ

លេខាធិការនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកខាងសិទ្ធិមនុស្សប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន សមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ឈរា ឌីតាន់	អគ្គលេខាធិការរាជរដ្ឋាភិបាល	ជាប្រធាន
២-លោក ស្វាយ ស៊ីថា	ទីប្រឹក្សាឯកឧត្តម សុខ អាន	សមាជិក
៣-លោក ចំរោម ម្រាលវ៉ាតូនី	ទីប្រឹក្សាឯកឧត្តម សុខ អាន	សមាជិក
៤-លោក សំ សុផល	ទីប្រឹក្សាឯកឧត្តម វ៉េង សេរីវុឌ្ឍ	សមាជិក
៥-លោកតំណាងក្រសួងយុត្តិធម៌		សមាជិក
៦-ក្រុមតំណាងក្រសួងមហាផ្ទៃ		សមាជិក
៧-ក្រុមតំណាងក្រសួងការពារជាតិ		សមាជិក
៨-លោកតំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ		សមាជិក
៩-លោកតំណាងក្រសួងពត៌មាន		សមាជិក
១០-លោកតំណាងរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា		សមាជិក
១១-លោកតំណាងគណៈកម្មការអន្តរក្រសួង ស្តីពីរោគអេដស៍		សមាជិក

ប្រការ ២ : ក្រុមការងារនេះមានភារកិច្ច :

- ត្រួតពិនិត្យលើរបាយការណ៍ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា របស់លោក មៃ គែល តើប៊ី តំណាងពិសេសរបស់លោកអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។
- ប្រមែប្រមូលឯកសារ វត្ថុតាងជុំវិញបញ្ហានៃការអនុវត្តន៍សិទ្ធិមនុស្សនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ធ្វើសេចក្តីព្រាងអត្ថបទក្នុងនាមរាជរដ្ឋាភិបាល ស្តីពីការរួមយោបល់កែលំអលើខ្លឹមសារនៃរបាយការណ៍ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា របស់លោក **មៃ គែល តើប៊ី** ។
- ដាក់សេចក្តីព្រាងអត្ថបទនេះ ថ្វាយនិងជូនសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ដើម្បីពិនិត្យ និង សំរេច រួចផ្ញើជូនលោកអគ្គលេខាធិការ អ.ស.ប អោយបានឆាប់រហ័ស ។

ប្រការ ៣ : ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសម្រេចការងារ និងមានសិទ្ធិ និង ភារកិច្ចអញ្ជើញតំណាងស្ថាប័នពាក់ព័ន្ធដទៃទៀតមកចូលរួម យោបល់ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា ប្រធានគណៈ កម្មការអន្តរក្រសួង ស្តីពីរោគអេដស៍ និងសាមីខ្លួនដែលមានចែងនៅក្នុងប្រការ ១ ត្រូវទទួល បន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះ ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៧១ សសរ.

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ចុះថ្ងៃទី ២៤ ខែ តុលាឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ជា ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការជំនួស ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវអញ្ជើញទៅចូលរួមប្រជុំប្រចាំឆ្នាំ របស់ធនាគារពិភពលោក ចាប់ពីថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃឯកឧត្តម **គាត ឈន់** ឬឯកឧត្តម **ស៊ុន ចាន់ថុល** វិលត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៧២ សសរ.

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៤ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីជំនួស ឯកឧត្តម **ថៅ ម៉េងលាត** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាដែលត្រូវអញ្ជើញទៅចូលរួមប្រជុំប្រចាំឆ្នាំ របស់ធនាគារពិភពលោក ចាប់ពីថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃ ឯកឧត្តម **ថៅ ម៉េងលាត** វិលត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាម ភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

II- ការងារបណ្ដាក្រសួង

១- ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣៣៦ សហវ.ថ

ស្ដីពីការបំពេញបន្ថែម

ចំណាត់ថ្នាក់ចំណូលថវិកាជូនជាតិរបស់រដ្ឋ

* * * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នសគ៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញប្រកាសលេខ ០០១ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្ដីពីចំណាត់ថ្នាក់ ចំណូល និងចំណាយថវិកាតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ចំណាត់ថ្នាក់ចំណូលថវិកាទូទៅរបស់រដ្ឋត្រូវបានបំពេញបន្ថែមដូចខាងក្រោម ៖

ចំណាត់ថ្នាក់ចំណូលចាស់	ចំណាត់ថ្នាក់ចំណូលថ្មីដែលត្រូវបំពេញបន្ថែម	សេចក្តីផ្សេងៗ
ប្រភេទទី ១ : ពន្ធ និង អាករ	ប្រភេទទី ១ : ពន្ធ និង អាករ	
ជំពូក ១២ : ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និងសេវាកម្ម	ជំពូក១២ : ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និងសេវាកម្ម	
ប្រការ ០៤ : អាករពិសេសលើទំនិញមួយចំនួន	ប្រការ ០៤ : អាករពិសេសលើទំនិញមួយចំនួន	
	កថាខ័ណ្ឌ ០១: ទំនិញផលិតក្នុងប្រទេស	បំពេញបន្ថែម
	កថាខ័ណ្ឌ ០២: ទំនិញនាំចូល	បំពេញបន្ថែម
ជំពូក ១៣ : ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស	ជំពូក ១៣ : ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស	
ប្រការ ០២ : អាករពីការនាំចេញ	ប្រការ ០២ : អាករពីការនាំចេញ	
កថាខ័ណ្ឌ ០១ : អាករគយពីការនាំចេញ	កថាខ័ណ្ឌ ០១ : អាករគយពីការនាំចេញ	
	វាក្យខ័ណ្ឌ ០១ : ការនាំចេញឈើ	បំពេញបន្ថែម
	វាក្យខ័ណ្ឌ ០២ : ការនាំចេញកៅស៊ូ	បំពេញបន្ថែម
	វាក្យខ័ណ្ឌ ០៣ : ការនាំចេញផលិតផលផ្សេងៗ	បំពេញបន្ថែម

ប្រការ ២ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

នាយ ចន

* * * *

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

ប្រកាស

ភ្នំពេញ , ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៧៦២ អក.ប្រក

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- ពិនិត្យសំណូមពរការងារក្នុងការបំពេញល័ក្ខខ័ណ្ឌរបស់ធនាគារពិភពលោក និងធនាគារ អភិវឌ្ឍន៍ អាស៊ី
- ពិនិត្យសំណូមពរចាំបាច់ នៃការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា

សំរេច

ប្រការ ១ : តម្លើងថ្លៃលក់ថាមពលអគ្គិសនីដល់អ្នកធ្វើសេវាកម្ម ចែកចាយថាមពលអគ្គិសនី ដែលបានចុះកិច្ច សន្យាជាមួយក្រុមហ៊ុនអគ្គិសនីកម្ពុជា ពី ២៤៥ រៀល មួយគីឡូវ៉ាត់ម៉ោងទៅ ២៨០ រៀលមួយគីឡូវ៉ាត់ម៉ោងចាប់ពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៥តទៅ។

ប្រការ ២ : ក្រុមហ៊ុនអគ្គិសនីកម្ពុជា ត្រូវផ្សព្វផ្សាយដល់អ្នកធ្វើសេវាកម្មអោយបានជ្រួតជ្រាបគ្រប់ៗគ្នា និង ណែនាំដល់សេវាករអោយអនុវត្តបានត្រឹមត្រូវតាមថ្លៃដែល រដ្ឋបានកំណត់ ៣៥០ រៀល ក្នុងមួយ គីឡូវ៉ាត់ម៉ោង ដោយជៀសវាងអោយបាននូវបាតុភាពតម្លើងថ្លៃលក់រាយដល់អ្នកប្រើប្រាស់ ។

ប្រការ ៣ : មន្ទីរនៃទីស្តីការ នាយកដ្ឋានជំនាញរបស់ក្រសួង និងក្រុមហ៊ុនអគ្គិសនីកម្ពុជា មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌភារកិច្ចរៀងៗខ្លួន តាមសេចក្តីសំរេចនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

អ៊ិត ប្រាំង

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៧៧១ : មសៈ ប្រក

រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញ ព្រះរាជក្រឹត្យរបស់សម្តេចព្រះបាទ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញលិខិតលេខ ២០៦ មស.បវ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការតម្លើងថ្នាក់ វី ការប៉ៀវត្សប្រចាំឆ្នាំរបស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
- បានឃើញ ការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ ដើម្បីរៀបចំតម្លើងថ្នាក់ឬការប៉ៀវត្សប្រចាំឆ្នាំ ជូនបុគ្គលិក មន្ត្រីរាជការសំរាប់ទីស្តីការក្រសួង អង្គភាពក្រុមហ៊ុន រោងចក្រចំណុះផ្ទាល់ និង អង្គភាព មន្ទីរឧស្សាហកម្មរ៉ែ និង ថាមពលខេត្ត–ក្រុង ដែលមានសមាសភាព ដូចខាងក្រោមនេះ ÷

១– ឯកឧត្តម **ពូ សុធីរៈ**	រដ្ឋមន្ត្រី	ជាប្រធាន
២–លោក **មាស ឡេង**	ប្រធាននាយកដ្ឋានបុគ្គលិក	ជាសមាជិក
៣– ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង		ជាសមាជិក
៤– អ្នករាជការ ២ នាក់		សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចដូចតទៅ ÷

ពិនិត្យពិចារណា និងវាយតំលៃពីលក្ខណៈសម្បត្តិ បុគ្គលិក មន្ត្រីរាជការម្នាក់ៗ ដែលត្រូវតំលើងថ្នាក់ឬការប៉ៀវត្សអោយបានត្រឹមត្រូវ តាមច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការ ស៊ីវិលត្រង់ចំណុចទី ៤ ។

ប្រការ ៣ : លោកនាយកខុទ្ទកាល័យ លោកប្រធានមន្ទីរ ប្រធានគ្រប់នាយកដ្ឋានសេនាធិការ ដែលពាក់ព័ន្ធ លោកប្រធានក្រុមហ៊ុន រោងចក្រចំណុះផ្ទាល់ និង លោកប្រធាន

មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល គ្រប់ខេត្ត–ក្រុង ត្រូវអនុវត្តន៍ក្នុង ក្របខ័ណ្ឌភារកិច្ចរៀងខ្លួនអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៣- ឧិស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ២៥២/៩៥ ពម.ប្រក

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

- បានឃើញ ព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតយល់ព្រមលេខ ១៦៤២ បល ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ពិនិត្យលើមតិយល់ព្រមលេខ ៤៥.៩៥ ទទក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៥ របស់អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា
- ពិនិត្យលើការសុំផ្លាស់ប្តូរកន្លែងធ្វើការរបស់សាមីខ្លួន

សម្រេច

ប្រការ ១ : ផ្ទេរលោក **កោង សារឿន** វិស្វករបច្ចេកទេសអគ្គិសនីបំរើការនៅអគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា នៃ ក្រសួងពត៌មាន អោយទៅបំរើការងារនៅក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា ត្រូវសំរួលផ្ទេរប្រាក់បៀវត្សទៅក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៥ នេះទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា និង សាមីខ្លួនមានភារៈអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែតុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ២៥៣/៩៥ ពម.ប្រក

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ របស់មន្ត្រី រាជការ

- បានឃើញ ព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតលេខ ៨៨៥ ស.ជ.ណ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស[illegible]ផ្ទៃ

សម្រេច

ប្រការ ១ : ផ្ទេរលោក **ចែម–ទុន្ត្រីការ** ប្រធានការិយាល័យ ទីភ្នាក់ងារសារពត៌មានខ្មែរ នៃ ក្រសួងពត៌មាន និង ក្របខ័ណ្ឌមួយកន្លែងអោយទៅបំរើការនៅ ក្រសួងមហាផ្ទៃ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ទីភ្នាក់ងារពត៌មានខ្មែរ ត្រូវសំរួលផ្ទេរទៅក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៥ នេះទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន ទីភ្នាក់ងារសារពត៌មានខ្មែរ «អា.កា.ប៉េ »អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និង សាមីខ្លួនមានភារអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រ ដ្ឋ ម ន្ត្រី

ហត្ថលេខា និង ត្រា

អៀង–មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ២៥៤/៩៥ ពម.ប្រក

* * *

ស្តីពីការផ្ទេរការងារមន្ត្រីរាជការ
របស់ ក្រសួង ពតិមាន

- បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការអោយប្រើសហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិល
- បានឃើញអនុក្រឹត្យ ស្តីពីការកែលំអរបៀបរៀប កម្មាភិបាល បុគ្គលិក កម្មករ រដ្ឋ លេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២
- យោងតាមចំណារយល់ព្រមរបស់ ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៥
- យោងតាមសំណើរបស់សាមីខ្លួន

សំរេច

ប្រការ ១ : អនុញ្ញាតផ្ទេរការងារ និង ក្របខ័ណ្ឌមួយកន្លែងរបស់ លោក **ស៊ុន សម័យ** ជាបុគ្គលិករបស់ អគ្គនាយកដ្ឋាន កាសែតកម្ពុជា នៃ ក្រសួងពត៌មាន ទៅបំរើការងារនៅសាលាខេត្ត តាកែវ នៃ ក្រសួងមហាផ្ទៃ វិញ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួន ត្រូវបានទទួលនៅ អង្គភាពថ្មី ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ តទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ , អគ្គនាយកដ្ឋានកាសែតកម្ពុជា និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ២៥៥/៩៥ ពម.ប្រក

* * *

បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩

- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសអោយប្រើច្បាប់ ស្តីពីរបបពត៌មាន នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតស្នើសុំរបស់ លោក **ចាន់ សារៈ** ចាងហ្វាងការផ្សាយទស្សនាវដ្តី « វិទ្យាយុទ្ធ» ចុះថ្ងៃទី ២០ កញ្ញា ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយទស្សនាវដ្តី « វិទ្យាយុទ្ធ » បោះពុម្ពផ្សាយដោយមានលោក **ចាន់ សារៈ** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ ប្រពៃណីល្អ និង ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងស្នើប្រគល់ទស្សនាវដ្ដី ចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **ចាន់ សារៈ** ចាងហ្វាងការផ្សាយទស្សនាវដ្ដី «វិទ្យាយុទ្ធ» និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ២៥៧/៩៥ ពម.ប្រក

* * *

ស្ដីពីការលុបឈ្មោះ មន្ត្រីរាជការ

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១-១១-១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី
- ពិនិត្យលើបំណារបញ្ជូនលេខ ៩៥ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់មន្ទីរពត៌មាន ខេត្តកណ្ដាល
- ពិនិត្យលើសំណើសុំឈប់បំរើការងាររបស់សាមីខ្លួន

សំរេច

ប្រការ ១ : លុបឈ្មោះ លោក **ជិន សុខុម** មន្ត្រីរាជការ នៃ មន្ទីរពត៌មានខេត្តកណ្ដាល ចាប់ [illegible] ខែ [illegible] ១៩៩៥ [illegible] ដោយសារ [illegible] ត្រូវឈប់បំរើ [illegible]

ប្រការ ២ : លោក **ខិន សុខុម** ដូចបានចែងក្នុងប្រការ ១ ត្រូវទទួលប្រាក់ឧបត្ថម្ភម្តងគត់ ស្មើ : ៤២.១៣០៛០០ គុណ ១០ :៤២១.៣០០៛០០«បួនរយម្ភៃមួយពាន់បីរយរៀលគត់»។

ប្រការ ៣ : អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ , មន្ទីរពេតិមានខេត្ត កណ្តាល និង សាមីខ្លួន មានភារៈអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៦៥១ អយក.ប្រក

ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា គុម្ពិគោល

មកជា សាលាបឋមសិក្សា « ហ៊ុន សែន - គុម្ពិគោល»

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធ អប់រំ នេះទូទៅ
- បានពិនិត្យលិខិតខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីទី ២ លេខ ៦៨-៩៥ ខនខ ចុះថ្ងៃទី ២៤-៧-១៩៩៥

- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡាខេត្ត ស្វាយរៀង ប្តូរឈ្មោះសាលាបឋមសិក្សា ភូមិគោល ក្នុងឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ខេត្ត ស្វាយរៀង មកជា សាលាបឋមសិក្សា «**ហ៊ុន សែន** ភូមិគោល» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥-១៩៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត ស្វាយរៀង សាលាបឋមសិក្សា ហ៊ុន សែន ភូមិគោល មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាមាន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៦៥២ អយក.ប្រក

ស្តីពីការប្តូរឈ្មោះ សាលាឧបសម្ព័ន្ធ បឋមសិក្សា ឧត្តរាស្ទឹត

ទៅជា សាលាបឋមសិក្សា « ត្នោតគោល »

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០–១១–១៩៨៦ ស្តីពីប្រព័ន្ធអប់រំនេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥–១០–១៩៨៦ ស្តីពីកំនត់ បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំ របស់ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកពញាឮ ខេត្តកណ្តាល លេខ ១៤០ អយក.ចខម ចុះថ្ងៃទី ២០ មេសា ១៩៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំ យុវជន និង កីឡា ស្រុកពញាឮ ខេត្តកណ្តាល ប្តូរឈ្មោះសាលាឧបសម្ព័ន្ធបឋមសិក្សទន្សាស្ថិតទៅជាសាលាបឋមសិក្សា «ព្រៃគោល» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥–១៩៩៦ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សាព្រៃគោល ត្រូវដឹកនាំដោយនាយកមួយរូប នាយករង ព្រមទាំងបុគ្គលិក ផ្សេងៗ តាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច នាយក នាយករង តាមគោលការណ៍កំនត់របស់រដ្ឋ ។

ប្រការ ៤ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត កណ្តាល ប្រធានការិយាល័យអប់រំ យុវជន និង កីឡាស្រុកពញាឮ និង សាលាបឋមសិក្សា ព្រៃគោល មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៦៥៣ អយក. ប្រក

ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា អំពិលបី

មកជា សាលាបឋមសិក្សា « ទេពប្រណម្យ »

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំ នេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥-១០-១៩៨៦ ស្តីពីកំនត់ បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំ របស់ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកពញាឮ ខេត្តកណ្តាល លេខ ១៤១ អយក. ចទម ចុះថ្ងៃទី ២០ មេសា ១៩៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំ យុវជន និង កីឡា ស្រុកពញាឮ ខេត្តកណ្តាល ប្តូរឈ្មោះសាលាបឋមសិក្សា អំពិលបី ទៅជា « សាលាបឋមសិក្សាទេពប្រណម្យ» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥-១៩៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ នឹង ចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្ត កណ្តាលប្រធានការិយាល័យអប់រំយុវជន និង កីឡាស្រុកពញាឮ សាលាបឋមសិក្សាទេពប្រណម្យ មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៥៤ អយក.ប្រក.

ប្រកាស

ស្តីពីការទទួលស្គាល់ សាលាបឋមសិក្សា អ្នកលាំងអាការ

និង សាលាបឋមសិក្សា អន្លង់ស្លែង

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_១៩៩៤
- បានឃើញក្រឹត្យ_ច្បាប់លេខ ៣ ក្រច. ចុះថ្ងៃទី ២០_១១_១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ. ចុះថ្ងៃទី ២៥_១០_១៩៨៦ ស្តីពីការកំណត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា

- បានពិនិត្យលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជននិងកីឡាស្រុកពញាឮ លេខ ១៤៥ អយក.ចទម. ចុះថ្ងៃទី ២០_៤_១៩៩៥ .
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបំណេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡាខេត្តកណ្តាលទទួលស្គាល់សាលាបឋមសិក្សត្រពាំងរការ និងសាលាបឋមសិក្សា អង្គស្នែង ពេញលក្ខណៈ ចាប់ពីឆ្នាំសិក្ស ១៩៩៥_៩៦ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា ដូចមានរាយនាមខាងលើនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់បឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : ប្រធានមន្ទីរក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានបំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ការិយាល័យអប់រំ យុវជន និងកីឡាស្រុកពញាឮ សាលា បឋមសិក្សាត្រពាំងរការ និង សាលាបឋមសិក្សាអង្គស្នែង មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ពត្តលេខានិងត្រា

តា សាឃាន

* * *

៥- ទីស្តីការរដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៨៧៧ បស្ព

ប្រកាស

ស្តីពីការទទួលស្គាល់ និងប្រគល់ភារកិច្ច

ជូនមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិដ្ឋាន

– [illegible]រាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ[illegible]រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត. ១០៩៤/៨៣ ចុះថ្ងៃទី ២៤_១០_១៩៩៤

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– យោងសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស.៩៤ ចុះថ្ងៃទី ៣០ តុលា ឆ្នាំ ១៩៩៤

– យោងលិខិតលេខ ១២៧ មស.ប្រខ. ចុះថ្ងៃទី ០៣_៣_១៩៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

ប្រការ ១ : ទទួលស្គាល់និងប្រគល់ភារកិច្ចជូនលោក **ឆិត្យ មុន្នីតិរង្សី** អោយបំរើការងារនៅខុទ្ទកាល័យ នៃក្រសួងគ្រប់គ្រងបរិដ្ឋាន ។

ប្រការ ២ : ការសាកល្បង ត្រូវគិតនិងអនុវត្តន៍ចាប់ពីថ្ងៃទី ០១_១១_១៩៩៥ ក្នុងការសាកល្បង សាមី ខ្លួនមានសិទ្ធិទទួលប្រាក់បៀវត្ស និងរបបឧបត្ថម្ភតែម្នាក់ឯង គត់ ។

ប្រការ ៣ : ការសាកល្បងសាមីខ្លួនទទួលប្រាក់ចំនួន ៩០ ភាគរយ ពីប្រាក់បៀវត្ស-សុទ្ធសាធរយៈ ពេល ១២ ខែ ចាប់ពីកំណត់ក្នុងប្រការ ២ តទៅ ។

ប្រការ ៤ : អគ្គនាយកខុទ្ទកាល័យ អង្គភាពដែលពាក់ព័ន្ធ និងលោក ទិត្យ មន្ទីភិរម្យ ត្រូវទទួល បន្ទុកអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សឹង អឿម

* * *

៦- ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ២១៣/៩៥ ក.ធ.ស

សេចក្តីសម្រេច

ស្តីពីការទទួលស្គាល់ព្រះវិហារ

ឆានអ៊ី ម៉ីលិក

* * *

រដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងទី ២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញសំណើសុំច្បាប់ និងសមាគមន៍ម៉ីលិក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៣។

សម្រេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍ អោយបើកព្រះវិហារ ផានអ៊ី ម៉ីលិក មួយកន្លែង ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ១១៤ ផ្លូវលេខ ១៣ សង្កាត់ផ្សារកណ្តាលទី ១ រាជធានីភ្នំពេញ។

ប្រការ ២ : ព្រះវិហារផានអ៊ីម៉ីលិក ត្រូវបានអនុញ្ញាតអោយផ្សព្វផ្សាយ នូវលទ្ធិសាសនាដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ព្រះវិហារផានអ៊ីម៉ីលិក ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការនិងសាសនា សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តផ្ទុយពីសេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសម្រេចនេះ មានអានុភាពតតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសម្រេច លេខ ២១៤/៩៥ ក.ធ.ស

ស្តីពីការអនុញ្ញាតបើកស្នាក់ការសហព័ន្ធក្រុមជំនុំ

គ្រិស្តបរិស័ទខ្មែរបាប់ទីស្ទ ខេត្តព្រៃវែង

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងទី ២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសំណូមពរ របស់សហព័ន្ធក្រុមជំនុំគ្រិស្តបរិស័ទខ្មែរបាប់ទីស្ទ ខេត្តព្រៃវែង ។

សម្រេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍ អោយបើកស្នាក់ការសហព័ន្ធក្រុមជំនុំគ្រិស្តបរិស័ទខ្មែរបាប់ទីស្ទខេត្តព្រៃវែងមួយកន្លែងស្ថិតនៅផ្ទះលេខ ១០០ ភូមិលេខ ៣ ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង ។

ប្រការ ២ : "សហព័ន្ធក្រុមជំនុំគ្រិស្តបរិស័ទខ្មែរបាប់ទីស្ទ ខេត្តព្រៃវែង " ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវលទ្ធិសាសនាគ្រិស្ត និង ផ្សព្វផ្សាយនូវឯកសារផ្សេងៗ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : "សហព័ន្ធក្រុមជំនុំគ្រិស្តបរិស័ទខ្មែរបាប់ទីស្ទ ខេត្តព្រៃវែង " ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា រក្សាអោយបាននូវសណ្តាប់ធ្នាប់ និង របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

សេចក្តីសម្រេច លេខ ២១៥/៩៥ ក.ធស.

« ស្តីពីការអនុញ្ញាតច្បាប់អោយបង្កើតសាខាព្រះវិហារសាសនា

ព្រះយេស៊ូគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងទី ២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសំណើសុំបង្កើតសាខានៃ "ព្រះវិហារសាសនា ព្រះយេស៊ូគ្រិស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ " ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍ អោយបង្កើតសាខាមួយកន្លែង ព្រះវិហារ " សាសនាព្រះ យេស៊ូគ្រិស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលមានអាស័យដ្ឋានស្ថិតនៅផ្ទះលេខ ៣០ ផ្លូវ លេខ ២៤៧ សង្កាត់បឹងកក់ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : "សាសនាព្រះយេស៊ូគ្រិស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ " ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវ លទ្ធិសាសនា ព្រះយេស៊ូគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : "សាសនាព្រះយេស៊ូគ្រិស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ " ត្រូវគោរពអោយបាន ម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : "សាសនាព្រះយេស៊ូគ្រិស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ "ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ រាល់ការអនុវត្តផ្ទុយពីសេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធ ត្រូវសហការអនុវត្តសេចក្តីសម្រេចខាងលើនេះ អោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឈៀន ឈុនរ័ត្ន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ២២៣/៩៥ កធស-ប្រក

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

* * *

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី ០១-១១-១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ដែលរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងធម្មការនិងសាសនា ។
- បានឃើញលិខិតលេខ ២៥២៤ អយក-ចក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជននិងកីឡា ។

សម្រេច

ប្រការ ១: ផ្ទេរក្របខ័ណ្ឌ ០២ កន្លែងនិងមន្ត្រី០២ នាក់ដូចមានរាយនាមខាងក្រោម :

១_ លោក **ឆាយ ពៅ** គ្រូមធ្យមសិក្សាកំរិត II ឯកទេសអង់គ្លេស

២_ លោក **ជុំ ជិនឡាយ** គ្រូមធ្យមសិក្សាកំរិត II ឯកទេសរូបវិទ្យា

បច្ចុប្បន្នបង្រៀននៅវិទ្យាល័យព្រះសុរាម្រិត នៃក្រសួងធម្មការត្រូវផ្លាស់អោយទៅបំពេញ ភារកិច្ចនៅក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ២: បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក **ឆាយ ពៅ** និង លោក **ជុំ ជិនឡាយ** ចាប់ផ្តាច់ ពីថ្ងៃ ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។

ប្រការ ៣: ខុទ្ទកាល័យ- នាយកដ្ឋានរដ្ឋបាលហិរញ្ញកិច្ច ការិយាល័យបុគ្គលិក វិទ្យាល័យព្រះសុរាម្រិត អគ្គាពុទ្ធិកសិក្សា និង លោកទាំងពីរដែលមានឈ្មោះ ក្នុងប្រការមួយត្រូវអនុវត្តរៀងៗ ខ្លួនតាមសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

ហត្ថលេខា និង ត្រា

ឈឿន ចន្ទណារិទ្ធ

* * *

៧- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១០៣៤ មស.មល

ស្តីពីការអនុញ្ញាតអោយផ្អាកការងារដោយគ្មានបៀវត្ស

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសារាចរណែនាំលេខ ០៣ សរ ចុះថ្ងៃទី ០៥-៣-១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការស៊ីវិលផ្អាកការងារមួយរយៈដោយគ្មានបៀវត្ស។
- [illegible] ពាក្យស្នើសុំរបស់សាមីខ្លួន ចុះថ្ងៃទី ១៩-៩-១៩៩៥
- ពិនិត្យលិខិតធានាអះអាងរបស់នាយក [illegible] អាណាព្យាបាលចុះថ្ងៃទី ៥ ខែ ១០ឆ្នាំ ១៩៩៥ បានអះអាងថាការផ្អាកការងារនេះមិនប៉ះពាល់ដល់ដំណើរការងាររបស់នាយក ដ្ឋាន ។

សម្រេច

ប្រការ ១ . អនុញ្ញាតអោយកញ្ញា **នាង មុំ** ផ្អាកការងារមួយរយៈដោយគ្មានប្រាក់បៀវត្សរយៈពេល [illegible]ខែ គិតពីថ្ងៃទី ០១.១០.១៩៩៥ ដល់ ០១.៤.១៩៩៦ ។

ប្រការ ២ . [illegible]ញ្ញរបស់សាមីខ្លួន ត្រូវរក្សាទុកក្នុងអង្គភាពរបស់ខ្លួនដដែល ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានក្របខ័ណ្ឌ នាយកដ្ឋានបៀវត្ស និងសាមីខ្លួនមានភារកិច្ច អនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

៨- ឧស្ដីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៩ បទ យក

ស្ដីពីលុបឈ្មោះមន្ត្រីបុគ្គលិករាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញ សេចក្ដីសំរេចលេខ ១៨៤ សសរ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្ដីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ
- បានឃើញ ច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល លេខ០៦នស ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។

សម្រេច

ប្រការ១: លុបឈ្មោះមន្ត្រី បុគ្គលិក រាជការ ចូលនិវត្តន៍ចំនួន ១៨ នាក់ ដូចមានរាយនាម ខាងក្រោម ចេញពីបញ្ជីក្របខ័ណ្ឌមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្ត-ក្រុង ចាប់ពីថ្ងៃទី ០១-១០- ១៩៩៥ តទៅ ÷

១_ លោក **អ៊ុន សមធិរៈ**	ខេត្តស្ទឹងត្រែង
២_ លោក **ឌី ឡូ**	ខេត្តស្ទឹងត្រែង
៣_លោក **អ៊ី ឆៀម**	ខេត្តបាត់ដំបង
៤_ លោក **ហង្ស ម៉ន**	ខេត្តបាត់ដំបង
៥_ លោក **មាស អ៊ឹម**	ខេត្តបាត់ដំបង
៦_ លោក **អ៊ី សារឿម**	ខេត្តបន្ទាយមានជ័យ
៧_ លោក **ចិន ឆល់**	ខេត្តបាត់ដំបង
៨_ លោក **ឃុន ឃួន**	ខេត្តកំពត
៩_ លោក **ម៉ិច ឆាត់**	ខេត្តរតនៈគិរី
១០_លោក **តី ឈាវ៉ាម**	ខេត្តមណ្ឌលគិរី
១១_លោក **កាន ឈី**	ខេត្តមណ្ឌលគិរី
១២_លោក **កើច ឃ្វេង**	ខេត្តមណ្ឌលគិរី
១៣_លោក **កែល យេន**	ខេត្តបន្ទាយមានជ័យ
១៤_លោក **ស្រី សារ៉ែត**	ខេត្តបន្ទាយមានជ័យ
១៥_លោក **ម៉ៅ ត៉ី**	ខេត្តកោះកុង
១៦_លោក **ចាន់ គីមស្រេង**	ខេត្តកំពង់ចាម
១៧_លោក **ឌួន ប៊ុល**	ខេត្តកណ្ដាល
១៨_លោក **ប៊ុត ម៉ៅ**	ខេត្តរតនៈគិរី

ប្រការ ២: ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្ត-ក្រុង និង សាមីខ្លួនទាំង ១៨ នាក់ ត្រូវទទួលបន្ទុកអនុវត្តន៍ តាមខ្លឹមសារនៃ ប្រកាសនេះ ។

ប្រការ ៣: ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អាន ឡាំគុ

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

[illegible]